ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ១០៦ កសក.ប្រក

# ប្រកាស
# ស្តីពី
# ការកំណត់តំបន់ជំងឺផ្តាសាយបក្សី

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលំអដីកសិកម្ម ឲ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វ និងផលិតផលមានដើមកំណើតពីសត្វ
- យោងលទ្ធផលវិភាគលេខ១០០/១៤ វ.ជ.ស.ប ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០១៤ របស់វិទ្យាស្ថានជាតិស្រាវជ្រាវបសុព្យាបាល
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ ១** : ត្រូវបានកំណត់តំបន់ជំងឺផ្តាសាយបក្សីចំនួន០១ (មួយ)កន្លែង នៅភូមិពាមល្វា ឃុំត្រពាំងជោ ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ។

**ប្រការ ២** : នាយកដ្ឋានផលិតកម្មនិងបសុពេទ្យ ត្រូវចាត់វិធានការបសុពេទ្យនៅតំបន់ផ្ទុះជំងឺផ្តាសាយបក្សីដែលមានចែងក្នុងប្រការ១ នៃប្រកាសនេះ ដូចខាងក្រោម៖
- បំផ្លាញចោលចំពោះបក្សីឈឺនិងឆ្លងជំងឺក្នុងតំបន់ផ្ទុះជំងឺទៅតាមវិធាននិងបច្ចេកទេសបសុពេទ្យ
- ត្រួតពិនិត្យលើការទិញ លក់ ឬការដឹកជញ្ជូនចំពោះបក្សីគ្រប់ប្រភេទចូល ចេញ ឬឆ្លងកាត់ក្នុងរង្វង់កាំប្រវែង០៣(បី) គីឡូម៉ែត្រពីចំណុចផ្ចិតនៃតំបន់ផ្ទុះជំងឺ។ តំបន់នេះជាតំបន់ត្រួតពិនិត្យ តាមដាន និងសិក្សាស្រាវជ្រាវប្រភពជំងឺផ្តាសាយបក្សីក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ និងត្រួតពិនិត្យចលនាបក្សីជាប្រចាំក្នុងរង្វង់ដែលមានកាំប្រវែង១០(ដប់) គីឡូម៉ែត្រ ពីចំណុចផ្ចិតនៃតំបន់ផ្ទុះជំងឺ។

**ប្រការ ៣** : ការរំសាយតំបន់ជំងឺផ្តាសាយបក្សីត្រូវកំណត់ដោយប្រកាសជាថ្មី។

**ប្រការ ៤** : ជនណាប្រព្រឹត្តល្មើសនឹងប្រការ២ និងប្រការ៣ នៃប្រកាសនេះត្រូវផ្តន្ទាទោសតាមមាត្រា៣១ នៃអនុក្រឹត្យលេខ១៦ អនក្រ.បក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០០៣ ស្តីពីការត្រួតពិនិត្យអនាម័យសត្វនិងផលិតផលមានដើមកំណើតពីសត្វ។

**ប្រការ ៥** : ប្រកាសឬសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ ៦** : អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធាននាយកដ្ឋានកិច្ចការរដ្ឋបាល ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានផលិតកម្មនិងបសុពេទ្យ និងប្រធានមន្ទីរកសិកម្មខេត្តកំពង់ស្ពឺ ត្រូវទទួលខុសត្រូវអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួនឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ២០១៤

**រដ្ឋមន្ត្រី**
**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**បណ្ឌិត អ៊ុក រ៉ាប៊ុន**

<u>កន្លែងទទួល៖</u>
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងការពារជាតិ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងយុត្តិធម៌
-ក្រសួងបរិស្ថាន
-ក្រសួងសុខាភិបាល
-ក្រសួងព័ត៌មាន
-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
-សាលាខេត្តកំពង់ស្ពឺ
" ដើម្បីជូនជ្រាប "
-ដូចប្រការ ៦
-ឯកសារ កាលប្បវត្តិ